KB PRASAC Bank

# ធនាគារ ខេប៊ីប្រាសាក់ ម.ក

# លក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណឥណទាន

បោះពុម្ពលើកទី ១

# មាតិកា

1. សេចក្តីផ្តើម....1
2. និយមន័យ....1
3. ប្រភេទប័ណ្ណ....2
4. រូបិយប័ណ្ណ....2
5. កម្រិតឥណទាន....2
6. ប្រភេទអ្នកប្រើប្រាស់ប័ណ្ណ....3
7. ទ្រព្យធានាសម្រាប់ប័ណ្ណឥណទាន....3
8. សុពលភាពនៃប័ណ្ណ....3
9. ម៉ោងប្រតិបត្តិការ....3
10. ប្រតិបត្តិការលើប័ណ្ណ....3
11. កម្រៃសេវា....4
12. ទំហំប្រតិបត្តិការ....4
13. អត្រាការប្រាក់ និងការគណនា....4
14. រយៈពេលអនុគ្រោះការប្រាក់សម្រាប់ប្រតិបត្តិការទិញទំនិញ/សេវាកម្ម....5
15. របាយការណ៍ប័ណ្ណឥណទាន....5
16. ទឹកប្រាក់សងអប្បបរមាប្រចាំខែ....5
17. កាលបរិច្ឆេទចុងក្រោយត្រូវបង់ប្រាក់....6
18. ការពិន័យលើការទូទាត់សងត្រលប់យឺត....6
19. ការស្នើសុំប័ណ្ណឥណទាន....6
20. ការស្នើសុំប័ណ្ណឥណទានរង....6
21. ការប្រគល់/ទទួលប័ណ្ណឥណទាន....7
22. ការបើកឱ្យដំណើរការប័ណ្ណឥណទាន....7
23. ការទូទាត់សងត្រលប់លើការប្រើប្រាស់ប័ណ្ណឥណទាន....7
24. គណនីទូទាត់ស្វ័យប្រវត្តិ....8
25. សេវាទូទាត់ស្វ័យប្រវត្តិ....8
26. ការប្រើប្រាស់លើសកម្រិតឥណទាន....8
27. ការស្នើសុំដំឡើង ឬ បន្ថយកម្រិតឥណទាន....9
28. ការស្នើសុំបិទប័ណ្ណឥណទាន....9
29. ការកែប្រែអត្រាការប្រាក់ កម្រៃសេវា ទំហំកំណត់ លក្ខខណ្ឌផ្សេងៗ និងការជូនដំណឹង....9
30. ការប្រើប្រាស់ប័ណ្ណឥណទានតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល....10
31. សុវត្ថិភាពនៃការប្រើប្រាស់ប័ណ្ណ....10
   31.1. ការថែរក្សាប័ណ្ណ និងព័ត៌មានប័ណ្ណ៖....10
   31.2. ការថែរក្សាលេខកូដសម្ងាត់ប័ណ្ណ (PIN)៖....11
   31.3. សារបោកបញ្ឆោតតាមរយៈអ៊ីម៉ែល ឬ ទូរស័ព្ទ៖....11

32. សិទ្ធិ និងកាតព្វកិច្ចរបស់លោក-លោកស្រី ..... 11
33. សិទ្ធិ និងកាតព្វកិច្ចរបស់ខេបីប្រាសាក់..... 12
34. ការទប់ស្កាត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម..... 13
35. ការដោះស្រាយវិវាទ..... 13
36. ច្បាប់គ្រប់គ្រង..... 14
37. ស្វ័យភាព នៃ បញ្ញត្តិ..... 14
38. ភាសា ..... 14

## 1. សេចក្តីផ្តើម

លក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណឥណទានរបស់ ធនាគារ ខេប៊ីប្រាសាក់ ម.ក តទៅហៅថា **«លក្ខខណ្ឌប្រើប្រាស់»** គឺជាកិច្ចព្រមព្រៀងរវាង **លោក-លោកស្រី** ជាមួយ ធនាគារ ខេប៊ីប្រាសាក់ ម.ក តទៅហៅថា **«ខេប៊ីប្រាសាក់»** ទាក់ទងទៅនឹងការប្រើប្រាស់ ប័ណ្ណឥណទាន របស់ ខេប៊ីប្រាសាក់។

នៅពេល លោក-លោកស្រី **យល់ព្រម** លើការស្នើសុំប្រើប្រាស់ប័ណ្ណឥណទាន មានន័យថា លោក-លោកស្រី បានអាន បានយល់ និងព្រមអនុវត្តនូវគ្រប់លក្ខខណ្ឌ ដែលមានចែងនៅក្នុងលក្ខខណ្ឌប្រើប្រាស់នេះ។

## 2. និយមន័យ

- ❖ លោក-លោកស្រី ៖ សំដៅលើ អតិថិជន ដែលបានស្នើសុំប្រើប្រាស់ប័ណ្ណឥណទានរបស់ខេប៊ីប្រាសាក់។
- ❖ ខេប៊ីប្រាសាក់ ៖ សំដៅលើ ធនាគារ ខេប៊ីប្រាសាក់ ម.ក ដែលជាអ្នកចេញប័ណ្ណ ជូន លោក-លោកស្រី។
- ❖ វីសា / VISA ៖ សំដៅលើ ក្រុមហ៊ុន Visa Inc., ដែលជាក្រុមហ៊ុនផ្តល់សេវាទូទាត់តាមប្រព័ន្ធអេឡិកត្រូនិកនៅជុំវិញសាកលលោកជាមួយនឹងប័ណ្ណឥណពន្ធ ប័ណ្ណឥណទាន ប័ណ្ណ Prepaid Cards និងប្រភេទប័ណ្ណផ្សេងទៀងដែលមានស្លាកសញ្ញា VISA ។
- ❖ ប័ណ្ណ ៖ សំដៅលើ ប័ណ្ណឥណទាន ដែលចេញដោយ ខេប៊ីប្រាសាក់។
- ❖ ប័ណ្ណឥណទាន ៖ សំដៅលើ ប័ណ្ណដែលយកទៅធ្វើប្រតិបត្តិការហិរញ្ញវត្ថុនានាដោយប្រើប្រាស់ទឹកប្រាក់កម្ចី ឬ កម្រិតឥណទានផ្តល់ដោយខេប៊ីប្រាសាក់។ លោក-លោកស្រី ត្រូវសងត្រលប់មកវិញនូវទឹកប្រាក់ដែលបានប្រើប្រាស់ រួមទាំងការប្រាក់ និងកម្រៃសេវាពាក់ព័ន្ធមកខេប៊ីប្រាសាក់ឱ្យបានទៀងទាត់តាមកាលបរិច្ឆេទកំណត់សងប្រាក់។
- ❖ ម្ចាស់ប័ណ្ណ ៖ សំដៅលើ បុគ្គល ដែលត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ ប័ណ្ណឥណទាន ដើម្បីធ្វើប្រតិបត្តិការផ្សេងៗ ដូចជា ទូទាត់ទំនិញ/សេវាកម្ម ដកប្រាក់។ល។
- ❖ ម្ចាស់ប័ណ្ណច្បង ៖ សំដៅលើ អតិថិជនដែលស្នើសុំប្រើប្រាស់ប័ណ្ណឥណទាន និងត្រូវទទួលរាប់រងលើការទូទាត់សងត្រលប់ រួមទាំងការប្រាក់ និងកម្រៃសេវាផ្សេងៗដែលបានមកពីប្រតិបត្តិការកើតឡើងពីប័ណ្ណច្បង និងប័ណ្ណរង។
- ❖ ម្ចាស់ប័ណ្ណរង ៖ សំដៅលើ អតិថិជនដែលប្រើប្រាស់ប័ណ្ណរង ដែលស្នើសុំបន្ថែមដោយម្ចាស់ប័ណ្ណច្បង ដើម្បីផ្តល់ឱ្យសមាជិកគ្រួសារ (សម្រាប់ឯកត្តជន) ឬ បុគ្គលិក (សម្រាប់នីតិបុគ្គល)។ កម្រិតឥណទានដែលផ្តល់ទៅប័ណ្ណរងអាចតូចជាង ឬ ស្មើកម្រិតឥណទាននៃប័ណ្ណច្បងអាស្រ័យលើការស្នើសុំដោយម្ចាស់ប័ណ្ណច្បង ឬ អ្នកតំណាងក្រុមហ៊ុនស្របច្បាប់។
- ❖ កម្រិតឥណទាន ៖ សំដៅលើ កម្រិតឥណទាន ឬ កម្ចីដែលផ្តល់ដោយខេប៊ីប្រាសាក់ ជូនអតិថិជន ដើម្បីប្រើប្រាស់ជាមួយប័ណ្ណឥណទាន។ ការអនុម័តលើការផ្តល់កម្រិតឥណទាន ត្រូវយោងទៅលើ

ការសិក្សាពីប្រវត្តិឥណទានរបស់អតិថិជន លទ្ធភាពសង និងលក្ខខណ្ឌផ្សេងៗកំណត់ដោយខេប៊ីប្រាសាក់។

❖ គណនីទូទាត់ស្វ័យប្រវត្តិ ៖ សំដៅលើ គណនីប្រាក់បញ្ញើសន្សំ ប្រើប្រាស់សម្រាប់ការទូទាត់សងត្រលប់នូវកម្រិតឥណទានដែលបានប្រើប្រាស់ ដោយខេប៊ីប្រាសាក់នឹងធ្វើការទូទាត់ចេញពីគណនីទូទាត់ស្វ័យប្រវត្តិ ទៅទូទាត់សងកម្រិតឥណទានដែលបានប្រើប្រាស់ នៅរៀងរាល់កាលបរិច្ឆេទទូទាត់ស្វ័យប្រវត្តិ។

❖ របាយការណ៍ប័ណ្ណឥណទាន ៖ សំដៅលើ របាយការណ៍សង្ខេបស្តីពីប្រតិបត្តិការកើតឡើងលើការប្រើប្រាស់ប័ណ្ណឥណទានក្នុងរយៈពេលមួយខែ។

❖ ទឹកប្រាក់សងអប្បបរមាប្រចាំខែ ៖ សំដៅលើ ចំនួនទឹកប្រាក់តិចបំផុត ដែលម្ចាស់ប័ណ្ណត្រូវធ្វើការទូទាត់មក ខេប៊ីប្រាសាក់ វិញជាប្រចាំខែ នៅក្នុងកាលបរិច្ឆេទចុងក្រោយត្រូវបង់ប្រាក់ (Repayment Due Date) ដើម្បីជៀសពីប្រាក់ពិន័យលើការទូទាត់សងយឺត (Late Payment Fee) ។

❖ កាលបរិច្ឆេទចុងក្រោយត្រូវបង់ប្រាក់ ៖ សំដៅលើ កាលបរិច្ឆេទចុងក្រោយដែលកំណត់ឱ្យម្ចាស់ប័ណ្ណត្រូវធ្វើការទូទាត់សងត្រលប់មកខេប៊ីប្រាសាក់វិញ នូវទឹកប្រាក់ត្រូវបង់អប្បបរមា ឬ ទឹកប្រាក់ត្រូវបង់សរុប។

❖ ការទូទាត់ស្វ័យប្រវត្តិ ៖ សំដៅលើ ការកំណត់ពេលវេលាជាក់លាក់មួយ ដើម្បីសងត្រលប់នូវទឹកប្រាក់ ដែលបានប្រើប្រាស់ជាមួយប័ណ្ណឥណទាន ដោយអតិថិជនអនុញ្ញាតឱ្យ ខេប៊ីប្រាសាក់ ធ្វើការកាត់ទឹកប្រាក់ចេញពីគណនីទូទាត់ស្វ័យប្រវត្តិនៅរៀងរាល់កាលបរិច្ឆេទនៃការទូទាត់ស្វ័យប្រវត្តិ។

## 3. ប្រភេទប័ណ្ណ

ប័ណ្ណឥណទានខេប៊ីប្រាសាក់ ត្រូវបានចែកចេញទៅតាមប្រភេទអតិថិជនដូចខាងក្រោម៖

| ប្រភេទអតិថិជន / Client Type | ប្រភេទប័ណ្ណ / Card Type |
|---|---|
| ឯកត្តជន (Individual) | 1. ប័ណ្ណវីសាក្លាស៊ិក \| Visa Classic Card<br>2. ប័ណ្ណវីសាហ្គោល \| Visa Gold Card<br>3. ប័ណ្ណវីសាផ្លាទីនីម \| Visa Platinum Card |
| នីតិបុគ្គល (Legal Entity) និង<br>គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ (Bank & FI) | 1. ប័ណ្ណវីសាអាជីវកម្ម \| Visa Business Card<br>2. ប័ណ្ណវីសាផ្លាទីនីមអាជីវកម្ម \| Visa Platinum Business Card |

## 4. រូបិយប័ណ្ណ

4.1. រូបិយប័ណ្ណនៃការស្នើសុំ កម្រិតឥណទាន (Credit Limit) គឺអនុញ្ញាតសម្រាប់តែ **ប្រាក់ដុល្លារអាមេរិក (USD)** តែមួយគត់។

4.2. ករណីអតិថិជនធ្វើប្រតិបត្តិការខុសពីរូបិយប័ណ្ណនៃកម្រិតឥណទាន ត្រូវយោងទៅតាមអត្រាប្តូរប្រាក់ប្រចាំថ្ងៃរបស់ខេប៊ីប្រាសាក់ និង/ឬ ក្រុមហ៊ុនវីសា នៅពេលធ្វើប្រតិបត្តិការជាក់ស្តែង។

## 5. កម្រិតឥណទាន

- កម្រិតឥណទាន (Credit Limit) ត្រូវបានផ្តល់ជូនអតិថិជនដោយផ្អែកទៅតាមប្រភេទអតិថិជននីមួយៗ ទៅតាមលក្ខខណ្ឌកំណត់ដោយខេប៊ីប្រាសាក់។

## 6. ប្រភេទអ្នកប្រើប្រាស់ប័ណ្ណ

| ល.រ | ប្រភេទអតិថិជន | ប្រភេទអ្នកប្រើប្រាស់ | បរិយាយ |
|---|---|---|---|
| 1 | សម្រាប់ឯកត្តជន (Individual) | ប័ណ្ណច្បង Primary Card | ▪ ជាអតិថិជនដែលខេប៊ីប្រាសាក់ផ្តល់កម្រិតឥណទានដើម្បីប្រើប្រាស់ |
| | | ប័ណ្ណរង Supplementary Card | ▪ សម្ព័ន្ធញាតិ ជាប្តី ប្រពន្ធ កូន ឪពុកម្តាយបង្កើត ឬ ឪពុកម្តាយក្មេក ជាមួយម្ចាស់ប័ណ្ណច្បង<br>▪ ប្រើប្រាស់កម្រិតឥណទានរួមគ្នាជាមួយម្ចាស់ប័ណ្ណច្បងអាចតិច ជាង ឬ ស្មើកម្រិតឥណទានម្ចាស់ប័ណ្ណច្បង<br>▪ ស្នើសុំប្រើប្រាស់ និងកំណត់កម្រិតឥណទានដោយម្ចាស់ប័ណ្ណច្បង |
| 2 | សម្រាប់នីតិបុគ្គល (Legal Entity) | ប័ណ្ណរង Supplementary Card | ▪ ជាថ្នាក់គ្រប់គ្រង ឬ បុគ្គលិកក្រុមហ៊ុន អាស្រ័យលើការចាត់តាំងពី អ្នកតំណាងស្របច្បាប់របស់ក្រុមហ៊ុន<br>▪ ស្នើសុំប្រើប្រាស់ដោយ អ្នកតំណាងស្របច្បាប់របស់ក្រុមហ៊ុន។ |

## 7. ទ្រព្យធានាសម្រាប់ប័ណ្ណឥណទាន

7.1. ការធានាលើការស្នើសុំប្រើប្រាស់ប័ណ្ណឥណទានខេប៊ីប្រាសាក់ មាន 02 (ពីរ) ប្រភេទ ទៅតាមការស្នើសុំពី អតិថិជន និងការសម្រេចពី ខេប៊ីប្រាសាក់ ដូចខាងក្រោម៖

| ល.រ | ប្រភេទ | បរិយាយ |
|---|---|---|
| 1 | ប័ណ្ណឥណទានគ្មានទ្រព្យធានា (Unsecured Credit Card) | ▪ ខេប៊ីប្រាសាក់នឹង ផ្តល់កម្រិតឥណទានដោយផ្អែកទៅលើប្រវត្តិនៃ ការប្រើប្រាស់ឥណទាន លទ្ធភាពសង និងលក្ខខណ្ឌផ្សេងៗទៀត ដែលតម្រូវដោយខេប៊ីប្រាសាក់។ |
| 2 | ប័ណ្ណឥណទានមានទ្រព្យធានា (Secured Credit Card) | ▪ តម្រូវឱ្យអតិថិជនដាក់ «សមតុល្យគណនីបញ្ញើមានកាលកំណត់ ឬ គណនីប្រាក់បញ្ញើសន្សំផ្សេងៗ ឬ ប្លង់ដី/ផ្ទះ/អគារ» ជាទ្រព្យធានា លើការស្នើសុំប័ណ្ណឥណទាន។ |

7.2. អតិថិជនអាចស្នើសុំប្តូរទ្រព្យធានាប័ណ្ណឥណទាននៅសាខាដើមស្នើសុំប័ណ្ណឥណទាន ដោយត្រូវគោរពទៅ តាមលក្ខខណ្ឌតម្រូវពីខេប៊ីប្រាសាក់។

## 8. សុពលភាពនៃប័ណ្ណ

8.1. ប័ណ្ណឥណទាន (គ្រប់ប្រភេទ) មានសុពលភាពប្រើប្រាស់រយៈពេល 05ឆ្នាំ ដូចមានបង្ហាញនៅលើប័ណ្ណ។

8.2. លោក-លោកស្រី ត្រូវស្នើសុំប្តូរប័ណ្ណថ្មីយ៉ាងតិច 30ថ្ងៃ មុនប័ណ្ណចាស់ផុតសុពលភាព។

## 9. ម៉ោងប្រតិបត្តិការ

- លោក-លោកស្រី អាចធ្វើប្រតិបត្តិការបានជាប្រចាំថ្ងៃ (24/7) លើកលែងតែមានការផ្អាកប្រតិបត្តិការជាបណ្តោះ អាសន្នដោយមានការជូនដំណឹងពី ខេប៊ីប្រាសាក់។

## 10. ប្រតិបត្តិការលើប័ណ្ណ

10.1. លោក-លោកស្រី អាចប្រើប្រាស់ប័ណ្ណ ដើម្បីធ្វើប្រតិបត្តិការបានគ្រប់ពេល ករណីមានកម្រិតឥណទានគ្រប់ គ្រាន់ និងត្រូវគោរពទៅតាមទំហំកំណត់ដោយខេប៊ីប្រាសាក់។

10.2. លោក-លោកស្រី ត្រូវធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់គ្រប់ព័ត៌មាននៃប្រតិបត្តិការឱ្យបានត្រឹមត្រូវ និងច្បាស់លាស់ មុនពេលអនុម័តប្រតិបត្តិការនានា (ដកប្រាក់ ទូទាត់ទំនិញ/សេវាកម្មតាមម៉ាស៊ីនឆូតកាត និងអនឡាញ (Online) ។ល។)

10.3. លោក-លោកស្រី យល់ព្រម បង់កម្រៃសេវាផ្សេងៗ ពាក់ព័ន្ធទៅនឹងការប្រើប្រាស់ និង/ឬ ធ្វើប្រតិបត្តិការតាមរយៈប័ណ្ណ និងយល់ព្រមឱ្យ **ខេប៊ីប្រាសាក់** ទូទាត់កម្រៃសេវា និង/ឬ ទូទាត់សងឥណទានដែលបានប្រើប្រាស់ដោយផ្ទាល់ចេញពីកម្រិតឥណទាន និង/ឬ គណនីទូទាត់ស្វ័យប្រវត្តិ របស់លោក-លោកស្រី។

## 11. កម្រៃសេវា

- កម្រៃសេវាលើការស្នើសុំប័ណ្ណ កម្រៃសេវាប្រចាំឆ្នាំ ការស្នើសុំកែប្រែ/មោឃភាពប័ណ្ណ កម្រៃសេវាលើការធ្វើប្រតិបត្តិការឆ្លងរូបិយប័ណ្ណ កម្រៃសេវាលើការទូទាត់សងឥណទានយឺត និងកម្រៃសេវាលើការធ្វើប្រតិបត្តិការហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុផ្សេងៗ គឺមានបង្ហាញនៅលើគេហទំព័រ/វេបសាយត៍ផ្លូវការ និង/ឬ គ្រប់ការិយាល័យខេប៊ីប្រាសាក់។

## 12. ទំហំប្រតិបត្តិការ

- ទំហំកំណត់នៃការធ្វើប្រតិបត្តិការផ្សេងៗតាមរយៈប័ណ្ណឥណទាន គឺមានបង្ហាញនៅលើវេបសាយត៍ផ្លូវការ និង/ឬ គ្រប់ការិយាល័យខេប៊ីប្រាសាក់។

## 13. អត្រាការប្រាក់ និងការគណនា

13.1. អត្រាការប្រាក់ លើការប្រើប្រាស់កម្រិតឥណទាន ដែលផ្តល់ជូនអតិថិជនត្រូវបានទូទាត់អាស្រ័យលើប្រភេទប្រតិបត្តិការ និងលក្ខខណ្ឌដូចខាងក្រោម៖

| ល.រ | ប្រភេទប្រតិបត្តិការ | អត្រាការប្រាក់ | លក្ខខណ្ឌនៃការទូទាត់ការប្រាក់ |
|---|---|---|---|
| 1 | ដាក់ប្រាក់<br>ពិនិត្យសមតុល្យកម្រិតឥណទាន<br>ប្តូរលេខកូដប័ណ្ណឥណទាន<br>បង្វិលទឹកប្រាក់ត្រលប់ (Refund)<br>បញ្ជូនទឹកប្រាក់ត្រលប់ (Reversal) | មិនមាន | មិនមាន |
| 2 | ដកប្រាក់ | 1.50% ក្នុងមួយខែ ឬ 18% ក្នុងមួយឆ្នាំ | ▪ **<u>គិតការប្រាក់ភ្លាមៗ</u>**រាប់ចាប់ពីថ្ងៃធ្វើប្រតិបត្តិការ រហូតដល់ថ្ងៃអតិថិជនសងត្រលប់គ្រប់ចំនួន |
| 3 | ទូទាត់ទំនិញ/សេវាកម្មតាមម៉ាស៊ីនឆូតកាត (POS) របស់ខេប៊ីប្រាសាក់ ឬ ធនាគារផ្សេង (ក្នុងប្រទេស/ក្រៅប្រទេស)<br>ទូទាត់ទំនិញ/សេវាកម្មតាមអនឡាញ | 1.20% ក្នុងមួយខែ ឬ 14.40% ក្នុងមួយឆ្នាំ | ▪ **<u>មិនគិតការប្រាក់</u>** រាប់ចាប់ពីថ្ងៃធ្វើប្រតិបត្តិការ រហូតដល់ថ្ងៃត្រូវទូទាត់សងត្រលប់ (Payment Due Date)<br>▪ **<u>គិតការប្រាក់លើទឹកប្រាក់ឥណទាន</u>**បានប្រើប្រាស់ដែលនៅសល់មិនទាន់សងត្រលប់ បន្ទាប់ពីហួសកាលបរិច្ឆេទសងប្រាក់ប្រចាំខែ ដោយរាប់ចាប់ពីថ្ងៃធ្វើប្រតិបត្តិការ។ |

❖ ការទូទាត់ការប្រាក់លើការទិញទំនិញ/សេវាកម្មតាមរយៈម៉ាស៊ីនឆូតកាត និងអនឡាញ ក្នុងករណី៖
1) **<u>អតិថិជនមិនបានទូទាត់សង ឬ ទូទាត់សងតិចជាង</u>** ចំនួនទឹកប្រាក់សងអប្បបរមាប្រចាំខែ (MMR) ស្មើនឹង 10% នៃចំនួនឥណទានសរុបដែលបានប្រើប្រាស់ ឬ
2) **<u>អតិថិជនបានទូទាត់សងស្មើ ឬ ធំជាង</u>** ចំនួនទឹកប្រាក់សងអប្បបរមាប្រចាំខែ (MMR) ប៉ុន្តែមិនគ្រប់ចំនួនទឹកប្រាក់សរុបដែលដែលបានប្រើប្រាស់ (100%)

❖ អត្រាការប្រាក់ នឹងត្រូវបានគណនាទៅលើទឹកប្រាក់ដែលនៅជំពាក់ ដោយគិតចាប់ពីថ្ងៃធ្វើប្រតិបត្តិការ (Transaction Date) ។

❖ មិនត្រូវបានគិតការប្រាក់ឡើយ ប្រសិនបើម្ចាស់ប័ណ្ណធ្វើការទូទាត់សងត្រលប់នូវទឹកប្រាក់សរុបដែលត្រូវបង់ (100%) នៃឥណទានដែលបានប្រើប្រាស់នោះ ទៅតាមកាលបរិច្ឆេទចុងក្រោយត្រូវបង់ប្រាក់ (Payment Due Date) ដូចបានបង្ហាញនៅលើរបាយការណ៍ប័ណ្ណឥណទាន (Credit Card Statement)។

13.2. ការប្រាក់ត្រូវបានគណនាទៅតាមវិធានដូចខាងក្រោម៖

$$I = (P \times r\% \times n) / 360$$

**ដោយ៖**

| | |
|---|---|
| I | ជាចំនួនការប្រាក់ដែលត្រូវទូទាត់ |
| P | ជាចំនួនទឹកប្រាក់សរុបដែលបានប្រើប្រាស់ជាក់ស្តែងនៅចុងថ្ងៃនីមួយៗ |
| r % | ជាអត្រាការប្រាក់ប្រចាំឆ្នាំ |
| n | ជាចំនួនថ្ងៃជាក់ស្តែងដែលបានប្រើប្រាស់កម្រិតឥណទានជាមួយប័ណ្ណឥណទាន។ |

## 14. រយៈពេលអនុគ្រោះការប្រាក់សម្រាប់ប្រតិបត្តិការទិញទំនិញ/សេវាកម្ម

- រយៈពេលលើកលែងអត្រាការប្រាក់សម្រាប់ការទិញទំនិញ ឬ សេវាកម្ម (Interest Free Period for Purchase) តាមរយៈម៉ាស៊ីនឆូតកាត និងអនឡាញ គឺអាចបានរហូតដល់ **47 ថ្ងៃ**។

## 15. របាយការណ៍ប័ណ្ណឥណទាន

15.1. របាយការណ៍ប័ណ្ណឥណទាន គឺជារបាយការណ៍សង្ខេបស្តីពីប្រតិបត្តិការកើតឡើងលើការប្រើប្រាស់ប័ណ្ណឥណទានក្នុងរយៈពេញមួយខែ។

15.2. របាយការណ៍ប័ណ្ណឥណទាន នឹងត្រូវបានផ្ញើដោយស្វ័យប្រវត្តិទៅកាន់អ៊ីម៉ែល (Email) របស់អតិថិជន ដែលបានបំពេញនៅលើពាក្យស្នើសុំប្រើប្រាស់ប័ណ្ណឥណទាន នៅរៀងរាល់**ថ្ងៃទី 01 នៃខែនីមួយៗ (Monthly)**។

## 16. ទឹកប្រាក់សងអប្បបរមាប្រចាំខែ

16.1. ទឹកប្រាក់សងអប្បបរមាប្រចាំខែ (MMR) គឺជាចំនួនទឹកប្រាក់អប្បបរមា ឬ ចំនួនទឹកប្រាក់តិចបំផុត ដែលកំណត់ដោយខេប៊ីប្រាសាក់សម្រាប់អតិថិជនទូទាត់សងត្រលប់លើការប្រើប្រាស់កម្រិតឥណទាន លើប័ណ្ណឥណទាន ជាប្រចាំខែ ត្រលប់មកខេប៊ីប្រាសាក់វិញ។

16.2. ចំនួនទឹកប្រាក់សងអប្បបរមាប្រចាំខែ (MMR) គឺ កំណត់យក **<u>10% នៃចំនួនកម្រិតឥណទានសរុបដែលបានប្រើប្រាស់</u>** ជាមួយប័ណ្ណឥណទាន។

16.3. ទឹកប្រាក់សងអប្បបរមាប្រចាំខែ (MMR) ត្រូវបានគណនាតាមរូបមន្តដូចខាងក្រោម៖

ទឹកប្រាក់សងអប្បបរមាប្រចាំខែ (MMR) = កម្រិតឥណទានសរុបដែលបានប្រើប្រាស់ប្រចាំខែ x 10%

## 17. កាលបរិច្ឆេទចុងក្រោយត្រូវបង់ប្រាក់

17.1. កាលបរិច្ឆេទចុងក្រោយត្រូវបង់ប្រាក់ គឺកំណត់យក**ថ្ងៃទី17 នៃ ខែ** និងមានបញ្ជាក់នៅលើរបាយការណ៍ប័ណ្ណឥណទាន។

17.2. កាលបរិច្ឆេទចុងក្រោយត្រូវបង់ប្រាក់ គឺជាពេលវេលាកំណត់ចុងក្រោយក្នុងការទូទាត់សងត្រលប់មកខេប៊ីប្រាសាក់វិញ នូវកម្រិតឥណទានដែលបានប្រើប្រាស់។ អតិថិជនតម្រូវឱ្យសងយ៉ាងតិចនូវចំនួនទឹកប្រាក់សងអប្បបរមា (MMR) ដើម្បីជៀសផុតពីប្រាក់ពិន័យលើការទូទាត់សងយឺត (Late Payment Fee) និងការបង្ខាំងប័ណ្ណឥណទាន (Block Credit Card) ពីការធ្វើប្រតិបត្តិការផ្សេងៗ។

17.3. ករណីកាលបរិច្ឆេទចុងក្រោយត្រូវបង់ប្រាក់ ប៉ះចំថ្ងៃចុងសប្តាហ៍ ឬ ថ្ងៃឈប់សម្រាក កាលបរិច្ឆេទបង់ប្រាក់ចុងក្រោយ (Payment Due Date) មិនត្រូវបានលើកទៅថ្ងៃធ្វើការបន្ទាប់ (Next Working Day) ឡើយ។

## 18. ការពិន័យលើការទូទាត់សងត្រលប់យឺត

- ខេប៊ីប្រាសាក់ នឹងធ្វើការទូទាត់កម្រៃសេវាលើការទូទាត់សងយឺត **<u>ចំនួន 2% (អប្បបរមា USD 2) នៃ ទឹកប្រាក់សងអប្បបរមាប្រចាំខែ</u>** ករណីអតិថិជនមិនបានទូទាត់សង ឬ ទូទាត់សងតិចជាង «ទឹកប្រាក់សងអប្បបរមាប្រចាំខែ» នៅថ្ងៃបន្ទាប់នៃ **កាលបរិច្ឆេទចុងក្រោយត្រូវបង់ប្រាក់** ដោយទូទាត់ចេញពីកម្រិតឥណទាន។

## 19. ការស្នើសុំប័ណ្ណឥណទាន

19.1. អតិថិជនអាចធ្វើការស្នើសុំប័ណ្ណឥណទាន តាមរយៈមធ្យោបាយណាមួយខាងក្រោម៖

1) តាមរយៈសាខាណាមួយនៅជិតបំផុត ឬ
2) តាមរយៈមន្ត្រីពាក់ព័ន្ធផ្នែកលក់ ឬ
3) តាមរយៈ កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល។

19.2. អតិថិជនត្រូវមានគណនីប្រាក់បញ្ញើសន្សំ ដើម្បីធ្វើជា **គណនីទូទាត់ស្វ័យប្រវត្តិ** (Auto Debit Account) សម្រាប់ការទូទាត់សងត្រលប់លើការប្រើប្រាស់ប័ណ្ណឥណទាន។

19.3. អតិថិជនត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងត្រូវផ្តល់ឯកសារគាំទ្រទៅតាមប្រភេទអតិថិជននីមួយៗ តាមការតម្រូវដោយខេប៊ីប្រាសាក់។

19.4. ខេប៊ីប្រាសាក់ នឹងផ្តល់ប័ណ្ណឥណទានជូនអតិថិជន ដោយផ្អែកទៅលើប្រវត្តិនៃការប្រើប្រាស់ឥណទាន លទ្ធភាពសង ទ្រព្យដាក់ធានា និងលក្ខខណ្ឌផ្សេងៗទៀតដែលតម្រូវដោយខេប៊ីប្រាសាក់។

## 20. ការស្នើសុំប័ណ្ណឥណទានរង

20.1. ម្ចាស់ប័ណ្ណច្បង ឬ អ្នកតំណាងស្របច្បាប់ក្រុមហ៊ុន អាចស្នើសុំប័ណ្ណរង និងត្រូវប្រើប្រាស់កម្រិតឥណទាន (Credit Limit) រួមគ្នាជាមួយម្ចាស់ប័ណ្ណច្បង ឬ ក្រុមហ៊ុន ដែល **<u>កម្រិតឥណទានអាចតិចជាង ឬ ស្មើនឹងកម្រិតឥណទាននៃប័ណ្ណច្បង/ក្រុមហ៊ុន</u>** ទៅតាមការស្នើសុំជាក់ស្តែង។

20.2. រាល់ប្រតិបត្តិការទូទាត់សង និងការចំណាយទាំងអស់របស់ប័ណ្ណរង គឺជាការទទួលបន្ទុកដោយម្ចាស់ប័ណ្ណច្បង ឬ ក្រុមហ៊ុន។

20.3. ម្ចាស់ប័ណ្ណរង ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ នូវរាល់ប្រតិបត្តិការទាំងឡាយណាដែលកើតឡើងពីការប្រើប្រាស់ប័ណ្ណឥណទានរបស់ខ្លួនដែលផ្ទុយពីច្បាប់ជាតិ និងច្បាប់អន្តរជាតិ។

20.4. តម្រូវឱ្យម្ចាស់ប័ណ្ណរង ធ្វើការបើកគណនីប្រាក់បញ្ញើសន្សំណាមួយជាមួយខេប៊ីប្រាសាក់ ដើម្បីងាយស្រួលផ្ទៀងផ្ទាត់លើការស្នើសុំផ្សេងៗពាក់ព័ន្ធការប្រើប្រាស់ប័ណ្ណឥណទាន។

## 21. ការប្រគល់/ទទួលប័ណ្ណឥណទាន

21.1. ការទទួលប័ណ្ណឥណទានសម្រាប់អតិថិជន មាន 02 ជម្រើសរួមមាន៖

1) អតិថិជនអញ្ជើញមកទទួលយកប័ណ្ណឥណទានដោយផ្ទាល់ ទៅសាខាដែលបានស្នើសុំ ឬ
2) មន្ត្រីពាក់ព័ន្ធនឹងការលក់ យកប័ណ្ណឥណទាន ទៅជូនអតិថិជនដល់ទីតាំងអតិថិជន។

21.2. អ្នកមានសិទ្ធិទទួលប័ណ្ណឥណទាន ត្រូវផ្អែកទៅតាមប្រភេទអតិថិជនដូចខាងក្រោម៖

| ល.រ | ប្រភេទអតិថិជន | ប្រភេទប័ណ្ណ | អ្នកមានសិទ្ធិទទួលប័ណ្ណ |
|---|---|---|---|
| 1 | ឯកត្តជន | ប័ណ្ណច្បង (Primary Card) | ម្ចាស់ប័ណ្ណច្បង |
| | | ប័ណ្ណរង (Supplementary Card) | ម្ចាស់ប័ណ្ណច្បង ឬ ម្ចាស់ប័ណ្ណរង (ទទួលប័ណ្ណរងផ្ទាល់ខ្លួន) |
| 2 | នីតិបុគ្គល | ប័ណ្ណរង (Supplementary Card) | អ្នកតំណាងស្របច្បាប់របស់ក្រុមហ៊ុន/ស្ថាប័ន ឬ ម្ចាស់ប័ណ្ណរង (ទទួលប័ណ្ណរងផ្ទាល់ខ្លួន) |
| 3 | គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ | | |

## 22. ការបើកឱ្យដំណើរការប័ណ្ណឥណទាន

អតិថិជនអាចបើកឱ្យដំណើរការប័ណ្ណឥណទាន និងកំណត់លេខកូដសម្ងាត់ប័ណ្ណ តាមមធ្យោបាយណាមួយខាងក្រោម៖

- កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល (KB PRASAC Mobile) ឬ
- ម៉ាស៊ីនអេធីអឹម (អតិថិជននឹងទទួលបានសារលេខកូដសម្ងាត់ចំនួន 06ខ្ទង់ (PIN) ទៅកាន់លេខទូរស័ព្ទដៃ និងតម្រូវឱ្យធ្វើការផ្លាស់ប្តូរទៅលេខកូដសម្ងាត់ផ្ទាល់ខ្លួនថ្មីនៅតាមម៉ាស៊ីនអេធីអឹម (ATM/CDM) ណាមួយរបស់ខេប៊ីប្រាសាក់)។

## 23. ការទូទាត់សងត្រលប់លើការប្រើប្រាស់ប័ណ្ណឥណទាន

23.1. រាល់ការប្រើប្រាស់ប័ណ្ណឥណទាន អតិថិជនមានកាតព្វកិច្ចត្រូវធ្វើការទូទាត់សងត្រលប់នូវកម្រិតឥណទាន ដែលបានប្រើប្រាស់ (Utilized Amount) ដោយត្រូវទូទាត់ជាប្រចាំខែ (Monthly Repayment) ទៅតាមកាលបរិច្ឆេទចុងក្រោយត្រូវបង់ប្រាក់ ដែលមានបង្ហាញនៅលើ «របាយការណ៍ប័ណ្ណឥណទាន/Credit Card Statement» ដែលផ្ញើទៅកាន់អ៊ីម៉ែលរបស់អតិថិជន។

23.2. អតិថិជន អាចស្នើសុំធ្វើការទូទាត់សងត្រលប់នូវឥណទានដែលបានប្រើប្រាស់ទៅតាមមធ្យោបាយខាងក្រោម៖

- ❖ ការប្រើប្រាស់សេវាទូទាត់ស្វ័យប្រវត្តិ (Auto Debit Service) ឬ
- ❖ ក្នុងករណីអតិថិជនចង់ទូទាត់មុនកាលបរិច្ឆេទនៃការទូទាត់ស្វ័យប្រវត្តិ (Advance Payment) អតិថិជនអាចធ្វើការទូទាត់ ដោយផ្ទាល់ទៅកាន់ប័ណ្ណឥណទាន បានតាមរយៈ៖
    1) កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល/KB PRASAC Mobile៖ អតិថិជន អាចធ្វើប្រតិបត្តិការផ្ទេរប្រាក់ពីគណនីទូទាត់ស្វ័យប្រវត្តិ ទៅកាន់ប័ណ្ណឥណទានរបស់ខ្លួន ឬ
    2) ស្នើសុំនៅតាមបញ្ជរបេឡារបស់ខេប៊ីប្រាសាក់/Counter ណាមួយ ឬ
    3) ដាក់ប្រាក់ទូទាត់ប័ណ្ណឥណទានតាមម៉ាស៊ីនដាក់ប្រាក់ខេប៊ីប្រាសាក់។

## 24. គណនីទូទាត់ស្វ័យប្រវត្តិ

24.1. អតិថិជនតម្រូវឱ្យមានគណនីប្រាក់បញ្ញើសន្សំណាមួយជាមួយខេប៊ីប្រាសាក់ ដើម្បីប្រើប្រាស់ក្នុងការទូទាត់សងត្រលប់ (For Repayment) ដោយស្វ័យប្រវត្តិលើការប្រើប្រាស់ប័ណ្ណឥណទាន។

24.2. សម្រាប់អតិថិជនឯកត្តជន (Individual) គណនីទូទាត់ស្វ័យប្រវត្តិអាចជាគណនីផ្ទាល់ខ្លួន ឬ គណនីរួម។ ករណីគណនីរួម (Joint Account) ការស្នើសុំត្រូវយោងតាម «លក្ខខណ្ឌប្រតិបត្តិការគណនី»។

## 25. សេវាទូទាត់ស្វ័យប្រវត្តិ

25.1. ការទូទាត់ស្វ័យប្រវត្តិ (Auto Debit Payment) គឺជាការកំណត់ពេលវេលាជាក់លាក់មួយ ដើម្បីសងត្រលប់នូវទឹកប្រាក់ដែលបានប្រើប្រាស់ជាមួយប័ណ្ណឥណទាន ដោយអតិថិជនអនុញ្ញាតឱ្យ ខេប៊ីប្រាសាក់ ធ្វើការកាត់ទឹកប្រាក់សងចេញពី **គណនីទូទាត់ស្វ័យប្រវត្តិ** នៅ **រៀងរាល់ថ្ងៃទី15 នៃខែ**។

25.2. អតិថិជនតម្រូវឱ្យធ្វើការកំណត់ការទូទាត់សងស្វ័យប្រវត្តិ នៅលើ **«ពាក្យស្នើសុំប្រើប្រាស់ប័ណ្ណឥណទាន»** ទៅតាមជម្រើសណាមួយខាងក្រោម៖

- ទូទាត់សរុប/Full Payment (សងត្រលប់ 100% នៃ កម្រិតឥណទានបានប្រើប្រាស់) ឬ
- ទូទាត់អប្បបរមា/Minimum Payment (សងត្រលប់ ត្រឹម 10% នៃ កម្រិតឥណទានបានប្រើប្រាស់)

25.3. នៅកាលបរិច្ឆេទទូទាត់ស្វ័យប្រវត្តិ ប្រព័ន្ធនឹងធ្វើការទូទាត់សងដោយទូទាត់ចេញពីគណនីទូទាត់ស្វ័យប្រវត្តិ (Auto Debit Account) ទៅសង **កម្រិតឥណទានបានប្រើប្រាស់ (Utilized Credit Limit)** ដោយស្វ័យប្រវត្តិតាមលក្ខខណ្ឌដូចខាងក្រោម៖

1) **ករណីអតិថិជនជ្រើសយក «ទូទាត់អប្បបរមា (10%)» ៖**
   - ករណីអតិថិជនមានសមតុល្យក្នុងគណនី ធំជាង ឬ ស្មើ 10% នោះប្រព័ន្ធនឹងធ្វើការទូទាត់សងប្រាក់ត្រឹម 10% តាមការជ្រើសរើសពីអតិថិជនលើពាក្យស្នើសុំប្រើប្រាស់ប័ណ្ណឥណទាន។
   - ករណីអតិថិជនមានសមតុល្យក្នុងគណនីតិចជាង 10% នោះប្រព័ន្ធនឹងធ្វើការទូទាត់សងប្រាក់ ទៅតាមសមតុល្យដែលមានជាក់ស្តែងនៅក្នុងគណនី ហើយប័ណ្ណឥណទាននឹងត្រូវបានបង្ខាំងដោយស្វ័យប្រវត្តិបន្ទាប់ពីផុតកាលបរិច្ឆេទសងប្រាក់ចុងក្រោយ (Payment Due Date)។

2) **ករណីអតិថិជនជ្រើសយក «ទូទាត់សរុប (100%)» ៖**
   - ករណីអតិថិជនមានសមតុល្យក្នុងគណនីស្មើ ឬ ធំជាង 100% នោះប្រព័ន្ធនឹងធ្វើការកាត់ទឹកប្រាក់ត្រឹម 100% នៃការប្រើប្រាស់កម្រិតឥណទានតែប៉ុណ្ណោះ។
   - ករណីអតិថិជនមានសមតុល្យក្នុងគណនី តូចជាង 100% នោះប្រព័ន្ធនឹងធ្វើការទូទាត់សងប្រាក់ទៅតាមសមតុល្យដែលមានជាក់ស្តែង។ ក្នុងករណីទូទាត់សងតូចជាង MMR (10% ) នោះប័ណ្ណឥណទាននឹងត្រូវបានបង្ខាំងដោយស្វ័យប្រវត្តិ បន្ទាប់ពីផុតកាលបរិច្ឆេទសងប្រាក់ចុងក្រោយ (Payment Due Date) ។

## 26. ការប្រើប្រាស់លើសកម្រិតឥណទាន

26.1. ការប្រើប្រាស់ទឹកប្រាក់ឥណទាន ដែលលើសពីកម្រិតឥណទានផ្តល់ជូនដោយខេប៊ីប្រាសាក់ មិនត្រូវបានអនុញ្ញាតឡើយ។

26.2. ប៉ុន្តែមានប្រតិបត្តិការមួយចំនួនដែលមិនមែនធ្វើឡើងដោយអតិថិជន ត្រូវបានអនុញ្ញាតឱ្យបន្ថែមលើសកម្រិតឥណទាន រួមមាន៖

1) កម្រៃសេវា (សេវាប្រចាំឆ្នាំ ប្រាក់ពិន័យ និងកម្រៃសេវាពាក់ព័ន្ធនានា)
2) ការប្រាក់ (គ្រប់ប្រភេទ)

3) ប្រតិបត្តិការផ្សេងៗទៀតដែលធ្វើឡើងដោយ ខេប៊ីប្រាសាក់។

## 27. ការស្នើសុំដំឡើង ឬ បន្ថយកម្រិតឥណទាន

27.1. ម្ចាស់ប័ណ្ណច្បង ឬ អ្នកតំណាងស្របច្បាប់ក្រុមហ៊ុន អាចស្នើសុំដំឡើង ឬ បន្ថយកម្រិតឥណទានសម្រាប់ប័ណ្ណច្បង ឬ ប័ណ្ណរង បានតាមរយៈ៖

- ✓ សាខាដើមស្នើសុំប័ណ្ណឥណទាន ឬ
- ✓ មន្ត្រីពាក់ព័ន្ធផ្នែកលក់ នៃសាខាដើមស្នើសុំប័ណ្ណឥណទាន។

27.2. ការស្នើសុំត្រូវគោរពទៅតាមលក្ខខណ្ឌកំណត់ដោយខេប៊ីប្រាសាក់។

27.3. ករណីការស្នើសុំប៉ះពាល់ដល់ការប្តូរប្រភេទប័ណ្ណឥណទាន អតិថិជនយល់ព្រមទូទាត់រាល់កម្រៃសេវាពាក់ព័ន្ធដូចជាកម្រៃសេវាលើការស្នើសុំប័ណ្ណថ្មី និង/ឬ កម្រៃសេវាប្រចាំឆ្នាំ ទៅតាមការកំណត់ដោយខេប៊ីប្រាសាក់។

## 28. ការស្នើសុំបិទប័ណ្ណឥណទាន

28.1. លោក-លោកស្រី អាចស្នើសុំបិទការប្រើប្រាស់ប័ណ្ណឥណទានជាលាយលក្ខណ៍អក្សរមកខេប៊ីប្រាសាក់ ឬ តាមមធ្យោបាយផ្សេងៗផ្តល់ដោយខេប៊ីប្រាសាក់។

28.2. ការស្នើសុំបិទប័ណ្ណឥណទាន គឺជាការបិទរាល់កិច្ចសន្យានៃការប្រើប្រាស់ប័ណ្ណឥណទានដែលផ្តល់ទៅម្ចាស់ប័ណ្ណច្បង ឬ ក្រុមហ៊ុន ។ រាល់ប័ណ្ណរង ដែលស្ថិតនៅក្រោមប័ណ្ណច្បង ឬ ស្នើសុំដោយក្រុមហ៊ុន នឹងត្រូវបានបិទដោយស្វ័យប្រវត្តិផងដែរ។

28.3. អតិថិជនតម្រូវឱ្យធ្វើការទូទាត់នូវរាល់កម្រិតឥណទាន ការប្រាក់ និងកម្រៃសេវាពាក់ព័ន្ធឱ្យបានរួចរាល់ ទើបអាចស្នើសុំបិទប័ណ្ណឥណទានបាន។

28.4. ក្នុងករណីមានទឹកប្រាក់ត្រូវទូទាត់បន្ថែមបន្ទាប់ពីប័ណ្ណឥណទានត្រូវបានបិទ ធនាគារ ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការទូទាត់ទឹកប្រាក់ទាំងនោះចេញពីគណនីទូទាត់ស្វ័យប្រវត្តិ ឬ គណនីផ្សេងៗរបស់អតិថិជន។

## 29. ការកែប្រែអត្រាការប្រាក់ កម្រៃសេវា ទំហំកំណត់ លក្ខខណ្ឌផ្សេងៗ និងការជូនដំណឹង

29.1. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការកែប្រែ អត្រាការប្រាក់ កម្រៃសេវា ទំហំកំណត់ និង/ឬ លក្ខខណ្ឌផ្សេងៗដែលត្រូវអនុវត្តចំពោះការប្រើប្រាស់ប័ណ្ណ របស់ លោក-លោកស្រី ដោយ ខេប៊ីប្រាសាក់ នឹងធ្វើការជូនដំណឹងទៅអតិថិជនឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវនៃច្បាប់។

29.2. ក្នុងរយៈពេលនៃការជូនដំណឹង ករណីមិនមានការតវ៉ាពី លោក-លោកស្រី ត្រូវសន្មតថា លោក-លោកស្រី បានយល់ព្រម និងទទួលយកការកែប្រែទាំងនោះមកអនុវត្តភ្លាមៗបន្ទាប់ពីការកែប្រែចូលជាធរមានដែលត្រូវបានផ្សព្វផ្សាយតាមរយៈមធ្យោបាយណាមួយខាងក្រោម៖

1). សាខាខេប៊ីប្រាសាក់ និង/ឬ

2). វេបសាយត៍ និង/ឬ បណ្តាញទំនាក់ទំនងសង្គមផ្លូវការរបស់ ខេប៊ីប្រាសាក់ និង/ឬ

3). ការផ្ញើសារ និង/ឬ អ៊ីម៉ែលទៅកាន់ លោក-លោកស្រី

4). ការផ្សព្វផ្សាយនៅលើទំព័រកាសែត ទស្សនាវដ្ដី កម្មវិធីខេប៊ីប្រាសាក់ម៉ូបាល សេវាខេប៊ីប្រាសាក់ឧបភើរេត ឬ មធ្យោបាយផ្សេងៗ ដែលខេប៊ីប្រាសាក់ បានជ្រើសរើស។ល។

29.3. អតិថិជនត្រូវបានសន្មតថាបានទទួលការជូនដំណឹងស្តីពីការកែប្រែខាងលើភ្លាមៗ បន្ទាប់ពីខេប៊ីប្រាសាក់បានធ្វើការចុះផ្សាយពីការកែប្រែព័ត៌មាននានារបស់ខ្លួនតាមរយៈមធ្យោបាយណាមួយក្នុងចំណោមមធ្យោបាយខាងលើ។

## 30. ការប្រើប្រាស់ប័ណ្ណឥណទានតាមរយៈកម្មវិធីខេប៊ីប្រាសាក់ម៉ូបាល

30.1. ម្ចាស់ប័ណ្ណច្បង អាចប្រើប្រាស់កម្មវិធីខេបីប្រាសាក់ម៉ូបាល ដើម្បីគ្រប់គ្រង និងប្រើប្រាស់ប័ណ្ណឥណទានដូចខាងក្រោម៖

1) ដាក់សំណើស្នើសុំប័ណ្ណឥណទានសម្រាប់ម្ចាស់ប័ណ្ណច្បង និងប័ណ្ណរង (Submit Request)
2) ពិនិត្យព័ត៌មានប័ណ្ណឥណទាន និងប្រតិបត្តិការ (View Card & Transaction Information)
3) បើកប័ណ្ណឱ្យដំណើរការប័ណ្ណច្បង និងប័ណ្ណរង (Activate Primary & Supplementary Card)
4) បង្កើតលេខកូដសម្ងាត់ថ្មីករណីភ្លេចសម្រាប់ប័ណ្ណច្បង និងប័ណ្ណរង (Reset New PIN)
5) បង្ខាំង / ដោះបង្ខាំងប័ណ្ណច្បង និង ប័ណ្ណរង (Block & Unblock Card)
6) ប្តូរប្រភេទការទូទាត់ស្វ័យប្រវត្តិ ពី 10% ទៅ/មក 100% (Change Auto Debit/Repayment Option)
7) ទូទាត់សងប័ណ្ណឥណទាន (Repayment)
8) អាចធ្វើការកំណត់ទំហំទឹកប្រាក់សម្រាប់ប្រតិបត្តិការ (Transaction Limit) សាច់ប្រាក់ ឬ ទិញទំនិញ/សេវាកម្ម របស់ប័ណ្ណច្បង និង/ឬ ប័ណ្ណរង (អប្បបរមា ត្រឹម USD 5)
9) ប្តូរចំនួនប្រតិបត្តិការរបស់ប័ណ្ណច្បង និង/ឬ ប័ណ្ណរងមកត្រឹម 1 (Number of Transaction)
10) បិទ/បើកសារជូនដំណឹងតាមរយៈអ៊ីម៉ែល និង
11) មុខងារ ជាច្រើនផ្សេងៗទៀត ទៅតាមការដាក់ឱ្យប្រើប្រាស់ដោយខេប៊ីប្រាសាក់។

30.2. **សម្រាប់ម្ចាស់ប័ណ្ណរង (For Supplementary) សម្រាប់ឯកត្តជន និងនីតិបុគ្គល**

1) ពិនិត្យព័ត៌មានប័ណ្ណឥណទាន និងប្រតិបត្តិការ (View Card & Transaction Information)
2) បើកប័ណ្ណឱ្យដំណើរការ (Activate Card)
3) បង្កើតលេខកូដសម្ងាត់ថ្មីករណីភ្លេច (Re-Issue New PIN)
4) បង្ខាំង / ដោះបង្ខាំងសម្រាប់ប័ណ្ណផ្ទាល់ខ្លួន (Block & Unblock Card)
5) ទទួលបានសារជូនដំណឹងលើប្រតិបត្តិការប័ណ្ណផ្ទាល់ខ្លួន
6) អាចធ្វើការកំណត់ទំហំទឹកប្រាក់សម្រាប់ប្រតិបត្តិការ (Transaction Limit) សាច់ប្រាក់ ឬ ទិញទំនិញ/សេវាកម្ម របស់ប័ណ្ណច្បង និង/ឬ ប័ណ្ណរង (អប្បបរមា ត្រឹម USD 5)
7) ប្តូរចំនួនប្រតិបត្តិការរបស់ប័ណ្ណរងមកត្រឹម 1 (Number of Transaction)
8) មុខងារ ជាច្រើនផ្សេងៗទៀត ទៅតាមការដាក់ឱ្យប្រើប្រាស់ដោយខេប៊ីប្រាសាក់។

## 31. សុវត្ថិភាពនៃការប្រើប្រាស់ប័ណ្ណ

31.1. **ការថែរក្សាប័ណ្ណ និងព័ត៌មានប័ណ្ណ៖**

31.1.1. សូមរក្សាទុកប័ណ្ណរបស់ លោក-លោកស្រី ឱ្យមានសុវត្ថិភាព។

31.1.2. សូមកុំប្រគល់ ប័ណ្ណ របស់ លោក-លោកស្រី ទៅឱ្យបុគ្គលណាម្នាក់ ដើម្បីយកទៅធ្វើប្រតិបត្តិការជំនួស ជាដាច់ខាត។

31.1.3. សូមកុំយកប័ណ្ណទៅធ្វើប្រតិបត្តិការជាមួយម៉ាស៊ីនអេធីអឹម (ATM) ឬ ម៉ាស៊ីនដាក់ប្រាក់ (CDM) ឬ ម៉ាស៊ីនឆូតកាត (POS) ឬ ប្រព័ន្ធអនឡាញ (Online/E-Commerce) ដែលមានភាពសង្ស័យ ឬ មានភាពមិនប្រក្រតី ឬ មិនស្គាល់ច្បាស់ឡើយ។

31.1.4. ត្រូវស្គាល់ និងដឹងពីប្រភេទអាជីវកម្មតាមអនឡាញ និងអាសយដ្ឋានគេហទំព័រ/វេបសាយត៍ដែលទិញទំនិញ/សេវាកម្ម ជាទីគួរឱ្យទុកចិត្តបាន មុនបើកបង្ហាញព័ត៌មានលម្អិតនៃប័ណ្ណ។

31.1.5. សូមកុំផ្តល់ព័ត៌មានប័ណ្ណដូចជា លេខប័ណ្ណ កាលបរិច្ឆេទផុតកំណត់ លេខកូដសម្ងាត់ប័ណ្ណ និង លេខ CVV ដែលមានចំនួន 03ខ្ទង់ (នៅផ្នែកខាងខ្នងប័ណ្ណ) ទៅឱ្យនរណាម្នាក់ជាដាច់ខាត ដោយសារព័ត៌មានទាំងនេះអាចប្រើប្រាស់ដើម្បីធ្វើប្រតិបត្តិការទិញទំនិញ/សេវាកម្មបាន។

31.1.6. សូមជូនដំណឹងមកខេបីប្រាសាក់ភ្លាមៗតាមរយៈលេខទូរស័ព្ទ ០២៣/០៨៦ ៩៩៩ ៩១១ ប្រសិនបើ លោក-លោកស្រីសង្ស័យ ឬ កត់សម្គាល់ថា **លេខកូដសម្ងាត់ប័ណ្ណ** ឬ **ព័ត៌មានប័ណ្ណ** ឬ **ប័ណ្ណ** របស់ លោក-លោកស្រីត្រូវបានគេដឹង ឬ ភ្លេច ឬ បាត់ ឬ ត្រូវបានលួច។ល។

31.2. **ការថែរក្សាលេខកូដសម្ងាត់ប័ណ្ណ (PIN)៖**

31.2.1. សូមធ្វើការផ្លាស់ប្តូរលេខកូដសម្ងាត់ប័ណ្ណ (PIN) នៅពេលទទួលបាន និងបំផ្លាញឯកសារដែលមាន ព័ត៌មានទាក់ទងនឹងលេខកូដសម្ងាត់នេះចោលភ្លាមៗ។

31.2.2. សូមចងចាំលេខកូដសម្ងាត់ប័ណ្ណ (PIN) ហើយកុំកត់ត្រាលើអ្វីមួយ ឬ ឱ្យអ្នកដទៃដឹង។

31.2.3. សូមកុំផ្តល់ ឬ ផ្ញើលេខប័ណ្ណ និង/ឬ លេខកូដសម្ងាត់ប័ណ្ណ (PIN) ឬ ព័ត៌មានប័ណ្ណ ឬ ព័ត៌មាន គណនី ដល់នរណាម្នាក់ ទោះដោយផ្ទាល់មាត់ ឬ សារអេឡិចត្រូនិច អាចជា អ៊ីម៉ែល, Facebook Messenger, Telegram... ជាដើម។

31.2.4. សូមកុំប្រើ ថ្ងៃខែឆ្នាំកំណើត លេខទូរស័ព្ទ លេខគណនី ឬ លេខរៀងដែលងាយស្រួលចាំ ជាលេខកូដ សម្ងាត់ប័ណ្ណ។

31.2.5. ត្រូវធានាថា ពេល លោក-លោកស្រី បញ្ចូលលេខកូដសម្ងាត់ (PIN) ដើម្បីប្រើប្រាស់ មិនអាចត្រូវ បានឃ្លាំមើលដោយនរណាម្នាក់ ឬ មិនមានមនុស្សនៅក្បែរអ្នកឡើយ។

31.2.6. សូមប្តូរលេខកូដសម្ងាត់ប័ណ្ណ (PIN) ជាប្រចាំ ឬ ក្នុងករណី លោក-លោកស្រី សង្ស័យថា ត្រូវបាន ដឹងដោយអ្នកដទៃ។

31.3. **សារបោកបញ្ឆោតតាមរយៈអ៊ីម៉ែល ឬ ទូរស័ព្ទ៖**

31.3.1. សូមប្រុងប្រយ័ត្នការបោកបញ្ឆោតយកព័ត៌មាន តាមរយៈអ៊ីម៉ែល វេបសាយត៍ កម្មវិធីដែលលោតផ្ទាំង មក (pop-up Windows) ឬ សារ SMS ដែលជាល្បិចឱ្យលោក-លោកស្រីបញ្ចូលព័ត៌មាន សំខាន់ៗដូចជា៖ លេខប័ណ្ណ លេខកូដសម្ងាត់ (PIN) លេខកូដ CVV និង កាលបរិច្ឆេទផុតកំណត់ ប័ណ្ណ។ល។

31.3.2. ប្រសិនបើ លោក-លោកស្រី ទទួលបានអ៊ីម៉ែល ដែលស្នើសុំព័ត៌មានទាំងនេះ សូមលុបចោលជា បន្ទាន់ និងមិនត្រូវចុចភ្ជាប់បណ្តាញ (Link) ឬ បើកឯកសារភ្ជាប់ណាមួយដែលមាននៅក្នុងអ៊ីម៉ែល នោះឡើយ។

31.3.3. ប្រសិនបើលោក-លោកស្រីមានចម្ងល់ ឬ ក៏មានមន្ទិលសង្ស័យលើវេបសាយត៍ ឬ អ៊ីម៉ែលណាមួយ សូមទំនាក់ទំនងមក ខេបីប្រាសាក់ តាមរយៈ info@kbprasacbank.com.kh ឬ ទូរស័ព្ទលេខ ០២៣/០៨៦ ៩៩៩ ៩១១ ជាបន្ទាន់។

## 32. សិទ្ធិ និងកាតព្វកិច្ចរបស់លោក-លោកស្រី

32.1. លោក-លោកស្រី ត្រូវធានាថាគ្រប់ព័ត៌មានដែលបានផ្តល់មក ខេបីប្រាសាក់ ជាព័ត៌មានត្រឹមត្រូវ និង ថ្មីបំផុត។ ករណី លោក-លោកស្រី ផ្តល់ព័ត៌មានមិនពិត ឬ ក្លែងក្លាយ នោះ លោក-លោកស្រី ត្រូវទទួលខុសត្រូវទាំង ស្រុងចំពោះមុខច្បាប់។

32.2. លោក-លោកស្រី ត្រូវធ្វើការត្រួតពិនិត្យកម្រៃសេវា និងព័ត៌មាននៃការទូទាត់ឱ្យបានត្រឹមត្រូវមុននឹងបញ្ជាប្រតិបត្តិការ។ រាល់ការបញ្ចូលព័ត៌មានខុស ឬ សមតុល្យលើស ឬ ខ្វះ ជាដើម ជាការទទួលខុសត្រូវទាំងស្រុងរបស់លោក-លោកស្រី។

32.3. លោក-លោកស្រី ត្រូវទទួលខុសត្រូវលើការប្រើប្រាស់ប័ណ្ណ និងមិនត្រូវប្រើប្រាស់ប័ណ្ណដើម្បីធ្វើប្រតិបត្តិការក្នុងគោលបំណងមិនស្របច្បាប់ជាតិ និងច្បាប់អន្តរជាតិឡើយ។

32.4. រាល់ការបាត់បង់ទឹកប្រាក់ក្នុងគណនីផ្ទាល់ខ្លួន ឬ គណនីរបស់អ្នកផ្សេង ដែលប្រព្រឹត្តដោយចេតនា ឬ អចេតនា ឬ ដោយការធ្វេសប្រហែស ឬ ដោយការសាកល្បងធ្វើប្រតិបត្តិការផ្សេងៗ ការលុកលុយរុករក ការកែបន្លំទិន្នន័យ ការលួចបន្លំដោយផ្ទាល់ ឬ ដោយប្រយោលតែម្នាក់ឯង ឬ ដោយមានការចូលរួមពីអ្នកដទៃ លោក-លោកស្រី ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់។

32.5. ក្នុងករណីដែលប័ណ្ណត្រូវបានលួច ឬ បាត់ លោក-លោកស្រីត្រូវជូនដំណឹងមកខេប៊ីប្រាសាក់ជាបន្ទាន់។ លោក-លោកស្រីត្រូវតែទទួលខុសត្រូវចំពោះប្រតិបត្តិការនានា ដែលបានកើតឡើងមុនពេលម្ចាស់ប័ណ្ណជូនដំណឹងមក ខេប៊ីប្រាសាក់អំពីការបាត់ប័ណ្ណ ឬ លួច។

32.6. លោក-លោកស្រី យល់ព្រមដោយឥតលក្ខខណ្ឌក្នុងការទូទាត់សំណងមក ខេប៊ីប្រាសាក់ ករណីមានការប្តឹងតវ៉ា ការទាមទារ ការទទួលខុសត្រូវ ការខាតបង់ ឬ ការចំណាយផ្សេងៗ ដែលខេប៊ីប្រាសាក់ទទួលរងទាក់ទងនឹងប្រតិបត្តិការតាមប័ណ្ណ ដោយការអនុវត្តបំពានរបស់ លោក-លោកស្រី លើលក្ខខណ្ឌនៃការប្រើប្រាស់ប័ណ្ណ រួមទាំងការខកខានមិនបានចាត់វិធានការទប់ស្កាត់ ការធ្វើប្រតិបត្តិការដោយគ្មានការអនុញ្ញាត ឬ ប្រតិបត្តិការក្លែងបន្លំ។ល។

32.7. លោក-លោកស្រី ត្រូវជូនដំណឹងមក ខេប៊ីប្រាសាក់ ជាលាយលក្ខណ៍អក្សរឱ្យបានទាន់ពេលវេលា ក្នុងករណីមានការផ្លាស់ប្តូរលេខទូរស័ព្ទ អ៊ីម៉ែល និង/ឬ ព័ត៌មានផ្ទាល់ខ្លួនផ្សេងៗ ដែលបានផ្តល់មក ខេប៊ីប្រាសាក់។ រាល់ការខាតបង់ ឬ ការពន្យារពេលផ្សេងៗដែលអាចកើតមកពីការខកខានមិនបានជូនដំណឹងមក ខេប៊ីប្រាសាក់ ជាការទទួលខុសត្រូវទាំងស្រុងរបស់ លោក-លោកស្រី។

32.8. លោក-លោកស្រី មិនត្រូវធ្វើប្រតិបត្តិការណាមួយដែលខុសច្បាប់ ឬ សកម្មភាពអាជីវកម្មណាមួយ ដែលត្រូវបានហាមឃាត់ឡើយ។

32.9. លោក-លោកស្រី មានសិទ្ធិក្នុងការផ្ទៀងផ្ទាត់ព័ត៌មាននៅក្នុង របាយការណ៍គណនី និងសាកសួរមក ខេប៊ីប្រាសាក់ ក្នុងករណីមានភាពមិនប្រក្រតីណាមួយកើតឡើង។

32.10. រាល់បញ្ហា ដែលកើតមានឡើងខុសប្រក្រតី ទាក់ទងនឹងសមតុល្យនៅក្នុងកម្រិតឥណទានដែលភ្ជាប់ជាមួយប័ណ្ណ លោក-លោកស្រី ត្រូវជូនដំណឹងមក ខេប៊ីប្រាសាក់ ឱ្យបានឆាប់រហ័ស។

## 33. សិទ្ធិ និងកាតព្វកិច្ចរបស់ខេប៊ីប្រាសាក់

33.1. ខេប៊ីប្រាសាក់ មានសិទ្ធិផ្ទៀងផ្ទាត់ព័ត៌មានរបស់ លោក-លោកស្រី និងសម្រេចក្នុងការផ្តល់ជូនប័ណ្ណដល់ លោក-លោកស្រី។

33.2. ខេប៊ីប្រាសាក់ នឹងអនុវត្តតាមការបញ្ជាលើប្រតិបត្តិការទូទាត់តាមរយៈប័ណ្ណរបស់លោក-លោកស្រី ប៉ុន្តែខេប៊ីប្រាសាក់ មិនទទួលខុសត្រូវ ក្នុងករណីដែល លោក-លោកស្រី បានបញ្ចូលព័ត៌មានខុស ឬ សមតុល្យលើស ឬ ខ្វះ ជាដើម។

33.3. ខេប៊ីប្រាសាក់ មានសិទ្ធិសហការជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការស៊ើបអង្កេត បង្ខាំង ឬ បញ្ឈប់ការប្រើប្រាស់ប័ណ្ណ របស់ លោក-លោកស្រី ដោយយោងលើច្បាប់ ឬ បទបញ្ញត្តិ ឬ ដីកាពីតុលាការ ឬ ការធ្វើប្រតិបត្តិការមិនស្របច្បាប់ណាមួយ។

33.4. ខេប៊ីប្រាសាក់ នឹងរក្សាការសម្ងាត់នូវរាល់ព័ត៌មានរបស់ លោក-លោកស្រី លើកលែងមានការយល់ព្រមពី លោក-លោកស្រី ឬ ច្បាប់តម្រូវ ឬ មានដីកាពីតុលាការបង្គាប់ឱ្យបង្ហាញព័ត៌មានសម្ងាត់ទាំងនោះ។

33.5. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការកំណត់ចំនួនដង និងចំនួនទឹកប្រាក់ សម្រាប់ការប្រើប្រាស់ប័ណ្ណ។

33.6. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការកែប្រែ ឬ អនុវត្តការយកកម្រៃសេវាប្រចាំឆ្នាំ/ប្រចាំខែ និង/ឬ កម្រៃសេវាពាក់ព័ន្ធលើការប្រើប្រាស់ និង/ឬ ធ្វើប្រតិបត្តិការតាមរយៈប័ណ្ណ អាស្រ័យលើលក្ខខណ្ឌ និងស្ថានភាពអាជីវកម្មជាក់ស្តែង។

33.7. ខេប៊ីប្រាសាក់ រក្សាសិទ្ធិក្នុងការធ្វើបច្ចុប្បន្នភាពជាប្រចាំលើប័ណ្ណ ដូចជា៖

- ដាក់បន្ថែមនូវមុខងារប្រតិបត្តិការថ្មីៗ ដោយយោងទៅតាមនិន្នាការទីផ្សារ និង/ឬ ការប្រែប្រួលបច្ចេកវិទ្យា ឬ
- លុប ឬ ផ្អាកជាបណ្តោះអាសន្នលើមុខងារណាមួយ ប្រសិនបើមានបញ្ហាបច្ចេកទេសណាមួយកើតឡើងដែលអាចមានផលប៉ះពាល់ដល់ប្រព័ន្ធធនាគារ ឬ ក្នុងគោលបំណងថែទាំប្រព័ន្ធ ឬ ផ្សេងៗ។

33.8. ប្រសិនបើប័ណ្ណរបស់លោក-លោកស្រី មិនអាចប្រើប្រាស់បានដោយករណីប្រធានសក្តិ ខេប៊ីប្រាសាក់ នឹងជួយដល់ លោក-លោកស្រី ក្នុងការរកដំណោះស្រាយ ឬ ផ្តល់ជំនួយការចាំបាច់ណាមួយយោងលើហេតុផលជាក់ស្តែង ប៉ុន្តែខេប៊ីប្រាសាក់មិនទទួលខុសត្រូវទៅលើហេតុការណ៍ទាំងនោះទេ។

33.9. ខេប៊ីប្រាសាក់រក្សាសិទ្ធិក្នុងការផ្អាកប្រតិបត្តិការពេលមានបញ្ហាផ្សេងៗ និងពេលមានការចាំបាច់ជាដើម។

33.10. ខេប៊ីប្រាសាក់រក្សាសិទ្ធិក្នុងការដោះស្រាយបញ្ហាជូនលោក-លោកស្រី ដោយអនុលោមតាមច្បាប់ និង/ឬ គោលការណ៍របស់ច្បាប់នៃព្រះរាជាណាចក្រកម្ពុជា និង/ឬ ខេប៊ីប្រាសាក់ និង/ឬ ស្ថាប័នទូទាត់អន្តរជាតិ (វីសា ឬ ផ្សេងៗ)។

## 34. ការទប់ស្កាត់ការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

- អនុលោមតាមបទប្បញ្ញត្តិទាំងឡាយនៃព្រះរាជាណាចក្រកម្ពុជា ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ខេប៊ីប្រាសាក់ អាចនឹងពន្យារពេល ឬ មិនធ្វើប្រតិបត្តិការជូន លោក-លោកស្រី ប្រសិនបើ ខេប៊ីប្រាសាក់ មានការជឿជាក់ដោយផ្អែកលើមូលហេតុដូចខាងក្រោម៖
  1). ខេប៊ីប្រាសាក់ មានការសង្ស័យចំពោះប្រភពដើមនៃប្រាក់ ឬ ប្រតិបត្តិការនោះ
  2). ប្រតិបត្តិការ ឬ គណនីនោះមានទំនាក់ទំនង ឬ ពាក់ព័ន្ធដោយផ្ទាល់ ឬ ដោយប្រយោលជាមួយនឹងសកម្មភាពល្មើសច្បាប់ណាមួយក្នុងព្រះរាជាណាចក្រកម្ពុជា ឬ ច្បាប់អន្តរជាតិ
  3). មានការបង្គាប់បញ្ជាពីតុលាការ ឬ ធនាគារជាតិ នៃ កម្ពុជា។ល។

## 35. ការដោះស្រាយវិវាទ

35.1. អតិថិជន មានរយៈពេល **30ថ្ងៃ** បន្ទាប់ពីថ្ងៃធ្វើប្រតិបត្តិការ សម្រាប់ដាក់បណ្តឹងពាក់ព័ន្ធនឹងប្រតិបត្តិការប័ណ្ណដែលមានវិវាទរួមមាន៖

- ប្រតិបត្តិការគ្មានការអនុញ្ញាត ឬ
- ប្រតិបត្តិការស្ទួន ឬ
- ប្រតិបត្តិការបន្លំ បោកប្រាស់ ឆបោក ឬ
- ប្រតិបត្តិការខុសចំនួនទឹកប្រាក់ ឬ
- ប្រតិបត្តិការខុសរូបិយប័ណ្ណ និង/ឬ
- ប្រតិបត្តិការផ្សេងៗដែលពាក់ព័ន្ធនឹងការទូទាត់ដោយប័ណ្ណ។

35.2. អតិថិជន អាចដាក់បណ្តឹងតាមរយៈទូរស័ព្ទមក **មន្ត្រីទំនាក់ទំនងអតិថិជន** (Call Center) ឬ ស្នើសុំជាលាយលក្ខណ៍អក្សរនៅសាខាខេប៊ីប្រាសាក់ណាមួយដែលនៅជិតបំផុត ដោយផ្តល់ព័ត៌មានពាក់ព័ន្ធនឹងគណនី ប័ណ្ណ ប្រតិបត្តិការ និង/ឬ ផ្តល់ឯកសារគាំទ្រតាមការស្នើសុំពីខេប៊ីប្រាសាក់។

## 36. ច្បាប់គ្រប់គ្រង

- លក្ខខណ្ឌប្រើប្រាស់នេះ ត្រូវបានគ្រប់គ្រង និងបកស្រាយដោយយោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា។

## 37. ស្វ័យភាព នៃ បញ្ញត្តិ

- ប្រសិនបើប្រការណាមួយនៃលក្ខខណ្ឌប្រើប្រាស់នេះ មិនអាចអនុវត្តបាន ឬ គ្មានសុពលភាពតាមផ្លូវច្បាប់ ប្រការទាំងនោះនឹងអស់សុពលភាពត្រឹមកម្រិតដែលប្រការនោះមិនអាចអនុវត្តបាន ឬ អសុពលភាពនៃប្រការនោះតែប៉ុណ្ណោះ ចំណែកប្រការផ្សេងៗទៀតនៃលក្ខខណ្ឌប្រើប្រាស់នេះនៅតែបន្តមានសុពលភាពអនុវត្តដដែល។

## 38. ភាសា

- លក្ខខណ្ឌប្រើប្រាស់នេះ ត្រូវបានធ្វើឡើងជាភាសាខ្មែរ និងអង់គ្លេស។ ករណីមានចំណុចណាមួយរវាងអត្ថបទទាំងពីរមានន័យមិនស្រប ឬ មិនស៊ីគ្នា នោះអត្ថបទជាភាសារខ្មែរចាត់ទុកជាផ្លូវការ៕

**៚ ចប់ ៚**